**ប្រការ ៦ :** គណៈកម្មាធិការជាតិ ( អនុគណៈកម្មាធិការជាតិ ) ខេត្ត ក្រុង ទូទាំងប្រទេស និងលោក គង់ គីរុន មាន ភារកិច្ចអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.គណៈកម្មាធិការជាតិ
ប្រធាន
ហត្ថលេខា
**ចណ្ឌ ម៉ូលីចណ្ឌ**

*****

*រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩៣*

# សេចក្តីសំរេចលេខ ៣៨ សសរ

# ស្តីពីការបង្កើតគណៈកម្មការជួសជុល និងកែលំអពហុកីឡាដ្ឋានអូឡាំពិក និងអាគារប្រជុំចតុមុខ

# រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័នព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមការចាំបាច់

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការមួយដើម្បីរៀបចំជួសជុល និងកែលំអពហុកីឡាដ្ឋានអូឡាំពិក និងអាគារប្រជុំចតុមុខ ដែលរួមមានសមាសភាពដូចតទៅ ÷

| | |
|---|---|
| ១. ឯកឧត្តម វណ្ណ ម៉ូលីវណ្ណ ទេសរដ្ឋមន្ត្រី | ជាប្រធាន |
| ២.តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | ជាអនុប្រធាន |
| ៣. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |

៤. តំណាងសាលាក្រុងភ្នំពេញ ជាសមាជិក

៥. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

**ប្រការ២ :** គណៈកម្មការនេះមានភារកិច្ចដូចតទៅ ÷

- សិក្សាលើកគំរោងជួសជុលនិងកែលំអពហុកីឡាដ្ឋានអូឡាំពិច និងអាគារប្រជុំចតុមុខអោយបានសមរម្យតាមស្ថានភាពប្រទេសជាតិ និងខាងអន្តរជាតិដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសំរេច ។

- ជួសជុលកែលំអពហុកីឡាដ្ឋានអូឡាំពិក និងអាគារប្រជុំចតុមុខក្រោយពីរាជរដ្ឋាភិបាលបានសំរេចលើគំរោងដែលបានស្នើឡើង ។

**ប្រការ ៣ :** គណៈកម្មការនេះមានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធមកប្រជុំ និងចូលរួមក្នុងការពិនិត្យដោះស្រាយការងារខាងលើនេះ ។

**ប្រការ ៤ :** គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីសំរួលការងារ ។

**ប្រការ ៥ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រតិភូនៃរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ និងឯកឧត្តម អស់លោកដែលមាននាមក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាពខ្ពស់បំផុតចាប់ពីថ្ងៃចុះព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

*****